# សេចក្តីប្រកាសព័ត៌មាន

## សភាពាណិជ្ជកម្មអឺរ៉ុប និងអង្គការសហប្រតិបត្តិការអន្តរជាតិអាល្លឺម៉ង់ (GIZ) សហការជាមួយ សមាគម TAFTAC ដើម្បីបើកដំណើរការមណ្ឌលអាជីវកម្មមានទំនួលខុសត្រូវ

**ទីក្រុងភ្នំពេញ ថ្ងៃទី២៩ ខែវិច្ឆិកា៖** សភាពាណិជ្ជកម្មអឺរ៉ុប និងអង្គការ Deutsche Gesellschaft Fur Internationale Zusammenarbeit (GIZ FABRIC) សហការជាមួយសមាគមវាយនភ័ណ្ឌ សម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា (TAFTAC) បានរៀបចំបើកដំណើរការផ្លូវការនូវមណ្ឌលអាជីវកម្មមានទំនួលខុសត្រូវ (RBH) នៅសណ្ឋាគារ Himawari Hotel នៅថ្ងៃទី២៨ ខែវិច្ឆិកា។

កម្មវិធីនេះត្រូវបានរៀបចំឡើងដើម្បីបង្ហាញមជ្ឈមណ្ឌល RBH នៅកម្ពុជា ដែលជាកន្លែងគាំទ្រដំបូងដែលផ្តល់សេវាជាច្រើនដែលមានពាក់ព័ន្ធនឹង**ការអនុវត្តធុរកិច្ចដែលមានទំនួលខុសត្រូវ** ដើម្បីគាំទ្រដល់វិនិយោគិន និងធុរកិច្ចក្នុងស្រុកធ្វើការអនុវត្តប្រកបដោយនិរន្តភាព។

ច្បាប់ថ្មីស្តីពីនិរន្តភាពគ្រប់គ្រងសកល និងការពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវផ្នែកសង្គម និងបរិស្ថាននឹងមានសារសំខាន់ចំពោះខ្សែច្រវាក់ផ្គត់ផ្គង់សកល ហើយក្រុមហ៊ុនដែលសម្របតាមការផ្លាស់ប្តូរនាពេលខាងមុខបានទាន់ពេលវេលាជាមុននឹងត្រៀមខ្លួនសម្រាប់ការអភិវឌ្ឍធុរកិច្ចនាពេលអនាគត។

ចំណុចសំខាន់បំផុតនៃច្បាប់ទាំងនោះ គឺជាច្បាប់ស្តីពីច្រវាក់ផ្គត់ផ្គង់អាល្លឺម៉ង់ដែលនឹងតម្រូវឱ្យក្រុមហ៊ុនអាល្លឺម៉ង់ធ្វើការទប់ស្កាត់ និងកាត់បន្ថយបញ្ហាដែលជាប់ពាក់ព័ន្ធនឹងសិទ្ធិមនុស្ស សុវត្ថិភាពកម្មករ និងនិរន្តភាពនៅទូទាំងច្រវាក់ផ្គត់ផ្គង់របស់ខ្លួនដោយក្នុងនោះរួមទាំងក្រុមហ៊ុនផ្គត់ផ្គង់នៅកម្ពុជាផងដែរ ដោយច្បាប់នេះនឹងត្រូវអនុវត្តចាប់ពីខែមករា ឆ្នាំ២០២៣ តទៅ។

នៅក្នុងពិធីនោះមានសន្ទរកថាថ្លែងស្វាគមន៍ពីសំណាក់អនុប្រធានផ្នែកកិច្ចសហប្រតិបត្តិការនៃស្ថានទូតអាល្លឺម៉ង់ លោកស្រីបណ្ឌិត Angelika Stauder ប្រធានកម្មវិធីសម្រាប់អភិបាលកិច្ចល្អ សិទ្ធិមនុស្ស និងការងារសមរម្យនៅប្រតិភូសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា លោកបណ្ឌិត Francesca Ciccomartino និងអនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម Tep Phiyorin។

ដូចដែលលោកស្រីបណ្ឌិត Stauder បានធ្វើការកត់សម្គាល់ មានប្រជាជនប្រមាណជា ២៨ លាននាក់ នៅទូទាំងពិភពលោកកំពុងធ្វើការងារដោយបង្ខំ ចំណែកកុមារ និងមនុស្សវ័យក្មេង ១៦០លាននាក់មានជាប់ពាក់ព័ន្ធនឹងពលកម្មកុមារដែលបង្ហាញពីតម្រូវការផ្តល់សេវានានាពីមជ្ឈមណ្ឌល RBH។



European Chamber of Commerce in Cambodia
#30 Preah Norodom Bred Bank building 3rd floor
Khan Daun Penh, Phnom Penh, Cambodia
+855 23 964 141 / +855 10 871 388
info@eurocham-cambodia.org
www.eurochamcambodia.org

នៅអំឡុងពេលថ្លែងសន្ទរកថាលើកទឹកចិត្តនោះ ឯកឧត្តមបណ្ឌិត សុក ស៊ីផាន់ណា បានលើកឡើងថា ប្រទេសកម្ពុជាមានគោជំហរច្បាស់លាស់ក្នុងអនុវត្តសិទ្ធិមនុស្ស និងលក្ខខណ្ឌពិនិត្យផ្ទៀងផ្ទាត់ភាពត្រឹមត្រូវ ដោយបានគិតគូរអំពីបញ្ហាទាំងនេះនៅក្នុងការ បង្កើតគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា ឆ្នាំ២០០១ ជាមួយអង្គការពលកម្មអន្តរជាតិ។

ឯកឧត្តមបានប្រសាសន៍ថា "ឥឡូវនេះ ត្រូវមានការចូលរួមចំណែកទាំងអស់គ្នាឆ្ពោះទៅការអនុវត្តកាតព្វកិច្ចគោរពច្បាប់ស្តីពីសិទ្ធិមនុស្ស និងបញ្ហាបរិស្ថាន។ បញ្ហានេះពាក់ព័ន្ធនឹងពេលវេលាដែលយើងបង្កើនការប្តេជ្ញាចិត្ត បង្កើនកិច្ចខិតខំរបស់យើង"។

"បញ្ហានេះតម្រូវឱ្យមានកិច្ចខិតខំប្រកបដោយមនសិការពីឧស្សាហកម្មនោះ។ តើច្បាប់នេះមានលក្ខណៈជាក់លាក់អ្វីខ្លះ ហើយមានឥទ្ធិពលយ៉ាងដូចម្តេចចំពោះយើងជាអ្នកផ្គត់ផ្គង់នៅទីនោះ? តើយើងអាចជួយអ្នកផ្គត់ផ្គង់ឱ្យអនុវត្តតាមច្បាប់ដោយរបៀបណា?"

លោក Ken Loo អគ្គលេខាធិការនៃសមាគម TAFTAC បានបង្ហាញពីធាតុចូលសំខាន់ៗពីឧស្សាហកម្មកាត់ដេរដោយកត់សម្គាល់ថា ការអនុលោមតាមស្តង់ដារថ្មីនឹងរងការប៉ះពាល់ដែលមិនគួរមើលរំលងនៅពេលប្រឈមជាមួយឧស្សាហកម្មដែលរកប្រាក់ចំណេញនោះ។

លោកបានលើកឡើងថា "វាមិនប៉ះពាល់ដល់យើងដោយផ្ទាល់នោះទេ ប៉ុន្តែ អតិថិជនរបស់យើងដែលជារងការប៉ះពាល់ដោយផ្ទាល់ ហើយធ្វើការទាមទារចំពោះយើង"។

លោកបានបន្ថែមថា "ក្នុងនាមជាវិនិយោគិនដែលមានទំនួលខុសត្រូវក្នុងឧស្សាហកម្មនេះនៅកម្ពុជា យើងចង់ធ្វើអ្វីដែលត្រឹមត្រូវ ទោះបីយើងមិនមានកាតព្វកិច្ចតាមផ្លូវច្បាប់ក៏ដោយ" ដោយកត់សម្គាល់ថា សមាគម TAFTA បានបង្កើតគណៈកម្មាធិការនិរន្តភាពរួចទៅហើយ។

លោកស្រី Sara Monti មន្ត្រីសម្របសម្រួលជាន់ខ្ពស់នៃមណ្ឌលអាជីវកម្មមានទំនួលខុសត្រូវ បានចែករំលែកបទបង្ហាញរួមមួយអំពីមជ្ឈមណ្ឌល RBH ដែលនិយាយអំពីគោលដៅ យុទ្ធសាស្ត្រ

និងសេវាថ្មីៗ។ នៅក្នុងចំណោមសេវាផ្សេងទៀត មជ្ឈមណ្ឌល RBH នឹងផ្តល់សេវាប្រឹក្សា ការណែនាំអំពីក្រុមហ៊ុនផ្តល់សេវាក្នុងស្រុកដែលមានវិជ្ជាជីវៈ និងសេវាបណ្តុះបណ្តាល។

"យើងនឹងប្តូរពីច្បាប់ទន់ភ្លន់ទៅជាច្បាប់ដែលត្រូវអនុវត្តជាចាំបាច់។ វាជានិន្នាការសកល ហើយក្រុមហ៊ុននឹងត្រូវការជំនួយក្នុងការអនុវត្តតាមច្បាប់ ដែលជាអ្វីដែលមជ្ឈមណ្ឌលធុរកិច្ចដែលមានទំនួលខុសត្រូវនឹងផ្តល់ជូននៅកម្ពុជា" នេះបើតាមការលើកឡើងរបស់លោកស្រី Monti។

ពិធីបើកដំណើរការមជ្ឈមណ្ឌលបានបញ្ចប់ដោយមានការលើកឡើងពីបរិបទច្បាប់ថ្មីនៅកម្ពុជា ដោយកត់សម្គាល់ថា នឹងត្រូវការវិធីសាស្រ្តរង់ចាំមើលដើម្បីពិនិត្យមើលអំពីពេលវេលា និងរបៀបអនុវត្តន៍លក្ខខណ្ឌតម្រូវទាំងនេះនៅប្រទេសកម្ពុជា។

ផ្តើមចេញពីទស្សនៈទូលំទូលាយ ប្រធានកម្មវិធីអង្គការពលកម្មអន្តរជាតិ លើក Sara Park បានលើកឡើងពីការតាមដានកម្រិត ១ រោងចក្រត្រូវមានការគ្រប់គ្រង ប៉ុន្តែ រោងចក្រតូចៗដែលមានកម្មករក្រៅផ្លូវការនៅតែរួចផុតពីការត្រួតពិនិត្យដដែល។

ទោះបីចំណុចជាក់លាក់នៃការអនុវត្តច្បាប់នោះមិនទាន់ប្រកាសក្តី ក៏មន្ត្រីសម្របសម្រួលអង្គការ GIZ FABRIC លោក Kristin Sommer បានលើកឡើងថា របៀបធ្វើធុរកិច្ចចាស់ហួសសម័យទៅហើយ ហើយក្រុមហ៊ុននៅអាល្លឺម៉ង់មិនអាចបញ្ជាក់អំពីការមិនយកចិត្តទុកដាក់ឡើយ ប្រសិនបើរកឃើញមានហានិភ័យជាមួយនឹងច្រវាក់ផ្គត់ផ្គង់របស់ខ្លួននោះ។

"ពួកគេមិនអាចមិនយកចិត្តទុកដាក់ជាមួយច្បាប់នេះឡើយ។ ប្រសិនបើគេដឹងអំពីហានិភ័យ ពួកគេត្រូវធ្វើការទប់ស្កាត់ និងកាត់បន្ថយហានិភ័យ បើមិនដូច្នោះទេ សកម្មភាពរបស់ពួកគេគឺជាការល្មើសច្បាប់។"

សភាពាណិជ្ជកម្មអឺរ៉ុប សូមថ្លែងអំណរគុណចំពោះវាគ្មិន និងគណៈកម្មាធិការវិច្ឆ័យទាំងអស់ដែលបានចូលរួមចំណែកនៅក្នុងការផ្តល់យោបល់ដ៏មានតម្លៃនេះ។

***

**អំពីសភាពាណិជ្ជកម្មអឺរ៉ុបប្រចាំនៅកម្ពុជា**

**សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា** (EuroCham Cambodia) ត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ2011 ដោយសមាគមធុរកិច្ចបារាំង អាល្លឺម៉ង់ និងអង់គ្លេសនៅកម្ពុជាដើម្បីបំពេញមុខងារសភាផ្លូវការនៃសហគមន៍ធុរកិច្ចអឺរ៉ុបនៅព្រះរាជាណាចក្រកម្ពុជា។ ចាប់តាំងពីពេលនោះមក សមាជិកសភាពាណិជ្ជកម្មអឺរ៉ុបបានកើនចំនួនដល់ជាង 300 និង 5 គណៈកម្មាធិការ ដែលមានប្រទេសអឺរ៉ុបចំនួន 11។ **សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា** មានសកម្មភាពស្នូលលើកកម្ពស់ គាំទ្រ និងតំណាងឱ្យសមាជិករបស់ខ្លួន និងផលប្រយោជន៍ធុរកិច្ចអឺរ៉ុបដោយសហការជាមួយរាជរដ្ឋាភិបាលកម្ពុជាដោយមានគោលបំណងធ្វើឱ្យដំណើរការធុរកិច្ច និងបរិយាកាសវិនិយោគកាន់តែប្រសិទ្ធភាព និងទទួលបានផ្លែផ្កាសម្រាប់ទាំងអស់គ្នា។

សកម្មភាពសំខាន់ៗរបស់សភាពាណិជ្ជកម្មអឺរ៉ុបមានដូចខាងក្រោម

- ពិគ្រោះយោបល់ និងតស៊ូមតិចំពោះបញ្ហាសំខាន់ៗដែលមានទាក់ទងនឹងការធ្វើធុរកិច្ចនៅកម្ពុជា។
- ជំរុញឱ្យមានការវិនិយោគមកប្រទេសកម្ពុជា។
- ធ្វើការកែលម្អការទទួលបានធុរកិច្ចអឺរ៉ុបមកទីផ្សារកម្ពុជា និងពីទីផ្សារកម្ពុជាទៅទីផ្សារអឺរ៉ុប និងសម្របសម្រួលធុរកិច្ចរវាងសហគ្រាសខ្នាតតូច និងមធ្យមកម្ពុជា និងរដ្ឋជាសមាជិកអឺរ៉ុប។
- ផ្តល់សេវាទាក់ទងនឹងសេដ្ឋកិច្ច ច្បាប់ បច្ចេកទេស ហិរញ្ញវត្ថុ ទីផ្សារ និងបញ្ហាផ្សេងទៀតនៅអឺរ៉ុប និងកម្ពុជា និងព័ត៌មានជាក់លាក់អំពីឧស្សាហកម្មដល់វិនិយោគិន។
- លើកកម្ពស់អត្តសញ្ញាណធុរកិច្ចអឺរ៉ុបកាន់តែរឹងមាំជាមួយសហគមន៍ធុរកិច្ចកម្ពុជា។
- សហការជាមួយភាគីពាក់ព័ន្ធកម្ពុជាក្នុងការគាំទ្រកំណើនសេដ្ឋកិច្ចកម្ពុជាប្រកបដោយបរិយាបន្ន និងនិរន្តភាព។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖

លោក Brian Badzmierowski មន្ត្រីជាន់ខ្ពស់ផ្នែកទំនាក់ទំនង

អ៊ីមែល៖ Pr.officer@eurocham-cambodia.org